# ច្បាប់
# ស្តីពីការធ្វើវិសោធនកម្ម
# មាត្រា ៩ និងមាត្រា ១០
# នៃច្បាប់ ស្តីពី
# សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

OA Channel

តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ទំនាក់ទំនង | https://t.me/oa_admin

# ព្រះរាជក្រម

នស/រកម/០៣១៣/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

# ច្បាប់
# ស្ដីពី
# ការធ្វើវិសោធនកម្មមាត្រា ៩ និងមាត្រា ១០ នៃច្បាប់
# ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
# នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រាមួយ.-**

មាត្រា ៩ និងមាត្រា ១០ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ៩.-ថ្មី**

របបស្ដីពីការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ។

**មាត្រា ១០.-ថ្មី**

របបបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ។

ការកែសម្រួលប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៧ ទល. ១៣០៣.២៤២

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា

ពេជ្រ ប៊ុនធិន

លេខៈ ៤៣៦ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

4/24